# <u>បទបញ្ញត្តមូលដ្ឋាន នៃ កិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស៍ ១៩៩១ ស្តីពីកម្ពុជា</u>

នៅក្នុងសម័យប្រជុំ លើកទីពីរ សន្និសិទ្ធបានអនុម័ត ឯកសារ ដូចខាងក្រោម ៖

I. កិច្ចព្រមព្រៀង ស្តីពីដំណោះស្រាយ នយោបាយរួមមួយ នៃជំលោះកម្ពុជា
II. កិច្ចព្រមព្រៀងស្តីពី អធិបតេយ្យភាព បូរណភាព និង ភាពមិនអាចរំលោភបាន នៃដែនដីអព្យាក្រិតភាព និង ឯក ភាពជាតិរបស់កម្ពុជា
III. សេចក្តីថ្លែងការណ៍ ស្តីពីការស្តារ និង កសាងប្រទេសកម្ពុជាឡើងវិញ

---------

*ដោយចង់ស្តារ* ឡើងវិញ និង ថែរក្សាសន្តិភាពនៅកម្ពុជា ជំរុញឱ្យមានការបង្រួបបង្រួមជាតិ និង ធានាឱ្យប្រជាជនកម្ពុជា ប្រើប្រាសសិទ្ធិស្វ័យសម្រេច តាមរយៈការបោះឆ្នោតដោយសេរី និង ត្រឹមត្រូវ ។

## ការបោះឆ្នោត

## មាត្រាទី ១២

ប្រជាជនកម្ពុជាត្រូវមាន សិទ្ធិសម្រេចពីអានាគត នយោបាយរបស់ខ្លួន តាមរយៈការបោះឆ្នោតដោយសេរី និង ត្រឹមត្រូវ ដើម្បីរើសសភាធម្មនុញ្ញមួយ ដែលត្រូវព្រាង និង អនុមតិរដ្ឋធម្មនុញ្ញកម្ពុជាមួយថ្មី ស្របទៅតាមមាត្រាទី ២៣ រួច ត្រូវក្លាយខ្លួនទៅជា សភានីតិបញ្ញត្តិ ដែលត្រូវបង្កើតរដ្ឋាភិបាលកម្ពុជាមួយថ្មី ។ការបោះឆ្នោតនេះ ធ្វើឡើងក្រោមការឧបត្ថម្ភ ដឹកនាំរបស់ អ.ស.ប. ក្នុងបរិយាកាសនយោបាយអព្យាក្រិតមួយ ដោយមានការគោរព ដោយពេញលេញដល់ អធិបតេយ្យ ភាពជាតិរបស់កម្ពុជា ។

---------

## សិទ្ធិមនុស្ស

## មាត្រាទី ១៥

១ - មនុស្សគ្រប់រូបនៅក្នុងប្រទេសកម្ពុជា និង ជនភៀសខ្លួន និង ជនផ្លាស់ប្តូរទីកន្លែង នៅកម្ពុជាទាំងអស់ ត្រូវមានសិទ្ធិ និង សេរីភាព ដែលមានចែងនៅក្នុង សេចក្តីប្រកាសជាសាកលពីសិទ្ធិមនុស្ស និង ក្នុងបណ្តាកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយ ដែលពាក់ព័ន្ធដល់ស្តីពីសិទ្ធិមនុស្ស ។

២ - ដើម្បីសម្រេចទិសដៅនេះ

ក - ប្រទេសកម្ពុជាសន្យាថានឹង:

- ធានាគោរព និង ប្រតិបត្តិតាមសិទ្ធិមនុស្ស និង សេរីភាព ជាមូលដ្ឋាននៅកម្ពុជា ។
- គាំទ្រសិទ្ធិរបស់ពលរដ្ឋកម្ពុជាទាំងអស់ ក្នុងការធ្វើសកម្មភាព ដែលជំរុញ និង ការពារសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន ។
- ចាត់បណ្តាវិធានការ ដ៏មានប្រសិទ្ធិភាព ដើម្បីធានាថា នយោបាយ និង អំពើប្រព្រឹត្តក្នុងអតីតកាល មិនត្រូវបានអនុញ្ញាតិឱ្យវិលត្រឡប់មកវិញជាដាច់ខាត ។
- ចូលរួមកិច្ចព្រមព្រៀងជាអន្តរជាតិទាំងឡាយ ដែលពាក់ព័ន្ធដល់ សិទ្ធិមនុស្ស ។

ខ - ហត្ថលេខីផ្សេងៗ ទៀត នៃកិច្ចព្រមព្រៀងនេះសន្យាថាជួយជំរុញ និង លើកទឹកចិត្តដល់ការគោរព និង ប្រតិបត្តិតាមសិទ្ធិមនុស្ស និងសេរីភាព ជាមូលដ្ឋាននៅកម្ពុជា ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង អន្តរជាតិទាំងឡាយ និង សេចក្តីសម្រេចទាំងឡាយរបស់មហាសន្និបាត អ.ស.ប. ដែលទាក់ទងនឹងបញ្ហានេះ ដើម្បីជាពិសេសការពារទប់ទល់នឹង ការកើតឡើងវិញ ការរំលោភសិទ្ធិមនុស្សជាថ្មីទៀត ។

---------

## ការធានាអន្តរជាតិ

## មាត្រាទី ១៨

កម្ពុជាសន្យាថា នឹងថែរក្សា ការពារ ហើយហត្ថលេខីឯទៀតៗ សន្យាថា ទទួលស្គាល់និងគោរព ចំពោះ អធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹតភាព និង ឯកភាពជាតិនៃកម្ពុជា ដូចមានចែងក្នុងកិច្ចព្រមព្រៀងមួយដាច់ដោយឡែក ។

------------------

## គោលការណ៍សម្រាប់រដ្ឋធម្មនុញ្ញថ្មីមួយរបស់កម្ពុជា

### មាត្រាទី ២៣

បណ្ដាគោលការណ៍ជាមូលដ្ឋាន ដោយរួមទាំងគោលការណ៍ ស្ដីពីសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន ក៏ដូចជា គោល-ការណ៍ស្ដីពីលក្ខន្តិកៈរបស់កម្ពុជា ជាប្រទេសអព្យាក្រិតមួយ ហើយដែលត្រូវបញ្ចូល ក្នុងរដ្ឋធម្មនុញ្ញកម្ពុជាថ្មីនោះ គឺមានចែងនៅក្នុង ឧបសម្ព័ន្ធទី ៥ ។

------------------

## ការស្ដារ និង កសាងឡើងវិញ

### មាត្រាទី ២៤

បណ្ដាហត្ថលេខីស្នើដំទទូច ឱ្យសហគមន៍អន្តរជាតិ ផ្ដល់ការគាំទ្រផ្នែកសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ការស្ដារ និង កសាងប្រទេសកម្ពុជាឡើងវិញ ដូចមានចែងនៅក្នុងសេចក្ដីប្រកាសដោយឡែកមួយ ។

---------------

## បទបញ្ញត្តិចុងក្រោយ

### មាត្រាទី ២៨

១ - បណ្ដាហត្ថលេខីទាំងឡាយ ត្រូវធ្វើតាមដោយស្មោះស្ម័គ្រ នូវរាល់កាតព្វកិច្ច ដែលមានសន្យានៅក្នុងកិច្ចព្រមព្រៀងនេះ ហើយត្រូវធ្វើសហប្រតិបត្តិការពេញលេញ ជាមួយអង្គការសហប្រជាជាតិ រួមទាំងការផ្ដល់ពត៌មានដែលអ៊ុនតាក់ "UNTAC" ត្រូវការក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។

២ - ការចុះហត្ថលេខា តាំងនាមឱ្យប្រទេសកម្ពុជា ដោយបណ្ដាលសមាជិក អេសអិនស៊ី ត្រូវបានចាត់ទុកដូចជាការសន្យាគោរពដោយភាគី និង កងទ័ពកម្ពុជាទាំងអស់ ចំពោះប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ។

### មាត្រាទី ៣០

កិច្ចព្រមព្រៀងនេះ និងចូលជាធរមាន ចាប់តាំងពីពេលចុះហត្ថលេខានេះទៅទៅ ។

### មាត្រាទី ៣១

កិច្ចព្រមព្រៀងនេះ នឹងត្រូវបើកចំហសម្រាប់ការចូលរួម របស់រដ្ឋទាំងអស់ ។ ឯកសារផ្លូវការនៃការចូលរួម ត្រូវតំកល់ទុក ជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង និង រដ្ឋាភិបាលនៃ សាធារណរដ្ឋឥណ្ឌូណេស៊ី ។ ចំពោះរដ្ឋនិមួយៗ ដែលយល់ព្រមចូលរួមនៅក្នុងកិច្ចព្រមព្រៀងនេះ កិច្ចព្រមព្រៀងត្រូវចូលជាធរមានបញ្ញត្តិ ចាប់តាំងពីពេលតំកល់ឯកសារផ្លូវការសុំចូលរបស់ខ្លួន ។ បណ្ដារដ្ឋដែលបានសុំចូល ត្រូវជាប់បញ្ញត្តិទៅនឹងកាតព្វកិច្ចដូចគ្នានឹង បណ្ដាហត្ថលេខីដទៃទៀតដែរ ។